# ល្ខោនតុក្កតាខ្មែរតាមសិលាចារឹក K-១៥៥

កន្លងមកអត្ថបទអំពី «ល្ខោនតុក្កតាខ្មែរ» ធ្លាប់បានផ្សព្វផ្សាយលើគេហទំព័រ AMS អរិយធម៌ខ្មែរម្តងរួចហើយ ដោយបានបង្ហាញព័ត៌មានទូទៅនៃល្ខោនតុក្កតាខ្មែរតែប៉ុណ្ណោះ។ ដោយឡែកចំពោះអត្ថបទនេះ នឹងបន្តបរិយាយអំពីល្ខោនតុក្កតាខ្មែរ ដោយផ្អែកលើព័ត៌មានក្នុងសិលាចារឹក K-១៥៥ ដែលបានបង្ហាញពាក់ព័ន្ធនឹងទម្រង់ទស្សនីយភាពតុក្កតានាសម័យអង្គរ ក៏ដូចជាតឹកតាងមួយបញ្ជាក់ថាខ្មែរយើងមានសិល្បៈនិងទម្រង់តុក្កតាតាំងពីយូរយារណាស់មកហើយ។

ខ្មែរយើងបានប្រើឈ្មោះមួយចំនួនពាក់ព័ន្ធនឹងតុក្កតា (មូលឬសំប៉ែត) ដូចជា៖ តុក្កតាយន្ត ឬល្ខោនយន្ត[១] របស់ក្មេងលេង[២] រូបតុក្កតាដើរដោយខ្សែឬយ៉ៃ (យ៉ៃ=សរសៃល្អិតឆ្មារដូចយៀងសរសៃឈូកជាដើម រង្វើលដែកឆ្មារសម្រាប់កម្រើកគ្រលែងជាជំនួយនាំគ្រឿងចក្រនាឡិកាដែលឥតប៉ោលឱ្យដើរ ដូចជាយ៉ៃនាឡិកា បង្គោលយ៉ៃ[៣] រូបចម្លាក់មានចលនាអាចកម្រើកបាន[៤] ទំពែកជល់គ្នា[៥] តុក្កតាធ្វើអំពីដីដុត ដែលអ្នកស្រុកនិយមហៅថា «ហ៊ីដុំដី» ក្នុងខេត្តបាត់ដំបង[៦] និងស្គរសូន្យរូប។[៧] យើងមិនបានដឹងច្បាស់អំពីប្រភេទតុក្កតានាសម័យដើម ថាជាប្រភេទតុក្កតា ដែលដើតដោយដងសន្ទូច (ដូចស្បែកតូច) ឬក៏ជាតុក្កតាដែលប្រើខ្សែពួរសម្រាប់ញាក់ ឬក៏មានលក្ខណៈផ្សេង។

ចំណាប់អារម្មណ៍និងការសិក្សាអំពីសិល្បៈនាសម័យមុនអង្គរនិងសម័យអង្គរ គឺមាននិងបានធ្វើជាច្រើនឆ្នាំណាស់មកហើយ។ ជាអាទិ៍ លោក ប៉ែរណា-ហ្វីលីព ហ្វ្រូលីយេ បានសរសេរអត្ថបទជាដំបូងនិងជាចុងក្រោយលើប្រធានបទនេះ ដែលមានចំណងជើងថា «របាំនិងតន្ត្រីនៅក្នុងរជ្ជកាលព្រះមហាក្សត្រអង្គរ» "*Danse et Musique sous les Rois*

---

[១] ២០០៣: ១១៩

[២] Headley et al. 1977: 322

[៣] ជួន ណាត ១៩៦៧: ៩៥៦; Thai Sovan 2004: 789

[៤] មាស វ៉ុងដេត (២០២២)

[៥] ក្រុមទំពែកជល់គ្នា វត្តកែវ ខេត្តបាត់ដំបង (២០២២)

[៦] ប៉ុល សំអឿន សាស្ត្រាចារ្យមហាវិទ្យាល័យសិល្បៈនាដសាស្ត្រសម័យមុនរបបប្រល័យពូជសាសន៍

[៧] គឹម ហាន (២០២២)

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

*d'Angkor"*។[៨] ក្រោយមកទៀត លោកស្រីសាស្ត្រាចារ្យបណ្ឌិត ពៅ សាវរស់ ក៏បានពិនិត្យមើលទៅលើប្រធានបទនេះជាពិសេសពីជំហរភាសាសាស្ត្រ សិលាចារឹក និងអត្ថបទខ្មែរដើម ខ្មែរកណ្តាល និងខ្មែរសម័យ។[៩]

ឯកសារទទួលបានពីការសិក្សាស្រាវជ្រាវនេះ ជាទម្រង់ព័ត៌មាននិងការពិពណ៌នាបែបចែដន្យ ដោយមានរៀបរាប់អំពីគ្រឿងបូជានិងអ្នកបម្រើ ដូចដែលយើងឃើញនៅក្នុងពាក្យ៖ អំណោយ ជំនូន និងខ្ញុំបម្រើ ដែលនៅក្នុងនោះមានស្រីអ្នករាំ តន្ត្រីករ-ការិនី និងអ្នកច្រៀង ជាអ្នកបម្រើអាទិទេពនៅក្នុងពិធីបួងសួងថ្វាយប្រចាំថ្ងៃ។[១០] ពាក្យពាក់ព័ន្ធនឹងសិល្បៈនាសម័យនោះមាន៖ រោង ក្រឡារោង (រោងសម្តែង ឬរោងលេង)។[១១] ពាក្យ «របាំ» (ការរាំ ឬរបាំ) គឺឃើញច្បាស់ក្នុងបរិបទមួយនៅលើសិលាចារឹក K-១៥៥ ដែលប្រើនៅពីក្រោយភ្ជាប់និងពាក្យ «ពេទានាតកៈ ឬ ពេទានាត្ត» (*pedānātaka* or *pedānātta*) ដែលមានន័យថា «ច្រើន ការប្រមូលផ្តុំ ក្រុមរបាំ»។[១២] ដូច្នេះ ពាក្យថា «របាំ» គឺសំដៅទៅលើក្រុមរបាំ។[១៣] ដោយឡែក ពាក្យថា «រនាំ» មានន័យថា «ការរាំ ឬអាជីពរាំ» និងពាក្យថា «រមាំ» មានន័យថា «អ្នករាំ។[១៤]

នៅលើសិលាចារឹកទាំងនេះ មានប្រយោគជាច្រើនដែលបង្ហាញថា ព្រះរាជាបូជាចំពោះអាទិទេពដោយថ្វាយរបាំឬក្រុមរបាំនៅក្នុងមហោស្រព ដែលអាចប្រារព្ធធ្វើឡើងរហូតដល់ទៅបួនដងក្នុងមួយឆ្នាំ។ ហើយក្នុងនោះ មានការរៀបរាប់ថាអ្នករាំស្ទើរតែទាំងអស់សុទ្ធសឹងជាស្ត្រី។[១៥]

ដោយឡែក សិលាចារឹក K-៩០ មានរៀបរាប់អំពីមហោស្រពដែលនៅក្នុងនោះមានទស្សនីយភាពសម្តែងកែកម្សាន្តធំៗ ដូចជារបាំ តន្ត្រី ល្បែង និងទស្សនីយភាពផ្សេងៗទៀត រួមមានទាំងការសម្តែងល្ខោន នាដកម្ម និងតុក្កតា។[១៦] ជាពិសេសពាក់ព័ន្ធនឹងអត្ថបទនេះ

---

[៨] Groslier 1965: 183-192; Pou 1997: 1

[៩] 1997: 229-248

[១០] Pou 1997: 230

[១១] Pou 1997: 230

[១២] Pou 1997: 230

[១៣] Pou 1997: 234

[១៤] Pou 1997: 234, 235

[១៥] Pou 1997: 234

[១៦] Pou 1997: 234

*គឺសិលាចារឹក K-១៥៥ ដែលរៀបរាប់អំពីដង្វាយថ្វាយទៅ សរៈស្វទី (Sarasvati) (អាទិទេពតំណាងឱ្យវោហារពីរោះនិងសិល្បៈ) ដែលនៅក្នុងនោះមានអ្នកសម្ដែងតុក្កតាស្រី។[១៧]*

*តាមការសង្កេតរបស់ខ្ញុំទៅលើសិល្បៈតុក្កតាខ្មែរបច្ចុប្បន្ន គឺមានជាតុផ្សំះ រូបតុក្កតា ការដើត កាយវិការល្ខោនត្រាប់ តន្ត្រី ចម្រៀង ការនិយាយ និងពំនោល ប្រកបដោយលក្ខណៈដ៏ពិសេសខុសពីតុក្កតាបរទេស គឺការដើតពីក្រោមតុ។*

*អត្ថបទល្ខោនតុក្កតាខ្មែរនេះ ផ្ដោតទៅលើសិលាចារឹក K-១៥៥ នៃប្រាសាទលលៃ ក្នុងស្រុកប្រាសាទបាគង ខេត្តសៀមរាប នាចុងសតវត្សទី៩ (៨៩៣)។ នេះក៏មានន័យថា សិល្បៈល្ខោនតុក្កតាខ្មែរ មានតាំងពីសម័យមុនកសាងប្រាសាទអង្គរវត្តមកម្ល៉េះ ដូចមានយោងនៅលើសិលាចារឹកខាងលើ ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី១ (៨៨៩-៨១០) ក្នុងជំនឿព្រហ្មញ្ញសាសនាដែលមានចែងអំពីសិល្បការិនីសម្ដែងសិល្បៈតុក្កតា «គូតុក្កតា» (Ku Tuktar) ដើម្បីឧទ្ទិសថ្វាយចំពោះអាទិទេព សរៈស្វទី (Sarasvati)។[១៩]*

*តាមឯកសារស្រាវជ្រាវ គេសម្ដែងល្ខោនតុក្កតានៅក្នុងពិធីបុណ្យទានសាសនានិងប្រពៃណី មានបញ្ចុះសព បញ្ចុះសីមាជាដើម ដើម្បីកំដរបរិយាកាសនិងកែកម្សាន្ត។*

*ក្រុមស្រាវជ្រាវរបស់យើងបានចុះទៅសិក្សាស្រាវជ្រាវ សិលាចារឹក ប្រាសាទលលៃ ដែលមាននៅលើគ្រប់ក្លោងទ្វារប្រាសាទ។ សិលាចារឹកខ្លះគេយកទៅទុក និងមានដាក់តម្កល់តាំងនៅសារមន្ទីរអង្គរ។ សិលាចារឹកបាគងនិងលលៃរក្សាទុកនៅវត្តលលៃតាំងពីជំនាន់សាធារណរដ្ឋ គឺសម័យ លន់ ណុល។[២០]*

*យើងត្រូវគិតពិចារណាឡើងវិញថា តើត្រូវធ្វើយ៉ាងណាដើម្បីគាំទ្រនិងលើកទឹកចិត្តសិល្បករសិល្បការិនីនៃសិល្បៈទម្រង់នេះឱ្យបន្ត ធ្វើឱ្យរស់ឡើងវិញ បង្កលក្ខណៈបំផុសបំផុលឱ្យមានការតម្លើងស្នាដៃថ្មីៗ និងមានការសម្ដែងសកម្មនិងគគ្រឹកគគ្រេងឡើង។*

*យ៉ាងណាមិញ ប្រសិនបើចង់ឱ្យមានការគាំទ្រ ជាពិសេសទស្សនិកជន សិល្បៈនេះក៏ត្រូវមានគុណភាពល្អប្រសើរ ខ្ជីខ្ជឹម ទំនើបរំភើបទាក់ទាញ អស្ចារ្យ ក៏ដូចជារហូតដល់ផ្ទុះ*

---

[១៧] Pou 1997: 232

[១៩] *ពេជ្រ ទុំក្រវិល ២០០៣: ១១៨*

[២០] *ព្រះតេជគុណ មុត្ត វិបុល ព្រះចៅអធិការវត្តលលៃ (ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២)*

*អត្ថបទដោយ៖ បណ្ឌិត សំ សំអាង*

ទៀតផង ទើបអាចទប់ទល់ប្រណាំងប្រជែងជាមួយនឹងទម្រង់សិល្បៈសម័យបច្ចេកវិទ្យាទំនើបដែលទស្សនិកជន ជាពិសេសក្នុងស្រទាប់យុវវ័យអាចទាញយកសិល្បៈនិងការកែកម្សាន្តយ៉ាងងាយស្រួលជាទីបំផុតពីទូរសព្ទបញ្ញាទំនើបបច្ចុប្បន្ននេះ។

គំនិតអភិរក្ស ថែរក្សា ប្រឌិតកម្ម បង្កើតថ្មី នវានុវត្តន៍ ជាកត្តាសំខាន់។ បច្ចុប្បន្ននេះ ជាការសោកស្ដាយពន់ពេក ដែលយើងមិនសូវមានអ្នកជួយគាំទ្រ លើកទឹកចិត្តដល់សិល្បករ សិល្បការិនីតុក្កតា ដែលជាកត្តាមួយធ្វើឱ្យគាត់បាក់ទឹកចិត្ត លែងចង់ធ្វើ លែងចង់បន្តការងារតុក្កតានេះទៅមុខទៀត។

ចំណុចសំខាន់គឺ៖ ១) ខ្មែរយើងធ្លាប់មានតុក្កតាតាំងតែពីសម័យមុនអង្គរ ២) តុក្កតាខ្មែរបានបាត់បង់ឈប់មានការសម្ដែងនាពេលបច្ចុប្បន្ន ៣) យើងត្រូវចូលរួមធ្វើយ៉ាងណាឱ្យសិល្បៈនេះមានជីវិតរស់ឡើងវិញ។

## ឯកសារពិគ្រោះ


ជួន ណាត. (១៩៦៧). *វចនានុក្រមខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ពេជ្រ ទុំក្រវិល. (២០០៣). *ទស្សនីយភាពខ្មែរ*. ភ្នំពេញ: រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

សំ សំអាង. (ខែកញ្ញា ឆ្នាំ២០០៣). «ល្ខោនតុក្កតាខ្មែរ,» *AMS អរិយធម៌ខ្មែរ*។

Coedès, George. (1937-1966). *Inscriptions du Cambodge* (8 vols.). Hanoi-Paris.

Groslier, Bernard-Philippe. (1965). "Danse et Music sous les Rois d'Angkor," *Felicitation Volumes of Southeast Asian Studies/Journal of the Siam Society*, *2*: 285-292.

Headley, Robert, and et al. (1977). *Cambodian-English Dictionary*. Washington, DC: The Catholic University of America Press.

Pou, Saveros. (December 1997). "Music and Dance in Ancient Cambodia as Evidenced by Old Khmer Epigraphy," *East and West*, *47*(1/4), 229-248.


អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

Thai, Sovan. (2004). *English-Khmer Dictionary*. Phnom Penh: Thai Sovan.

Vickery, Michael. (Janvier 1999). "The Khmer Inscriptions of Roluos (Preah Ko and Lolei):

Documents from a Traditional Period in Cambodian History," *Seksa Khmer*, (Nouvelle Série No. 1), 1-30.

គឹម ហាន. (២០២២). *បទសម្ភាសន៍. ព្រៃវែង។*

មាស វ៉ុងដេត. (២០២២). *បទសម្ភាសន៍. ខេត្តបន្ទាយមានជ័យ។*

មុត្ត វិបុល. (២០២២). *បទសម្ភាសន៍. ខេត្តសៀមរាប។*

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION